## ពិធីបុណ្យភូមិ នៅភូមិកោះកេរ (កម្តេច)

ដោយ ព្រាន់ សុភារៈ និងថូ ថុន

ជីវភាពប្រចាំថ្ងៃរបស់មនុស្សដែលរស់នៅក្នុងសហគមន៍ ក្រៅពីការធ្វើកសិកម្ម និងមុខរបរចិញ្ចឹមជីវិត គឺប្រជាជនទាំងនោះ រមែងមានធ្វើពិធីបុណ្យនានាដែលប្រព្រឹត្តនៅតាមសហគមន៍របស់ពួកគេរស់នៅផងដែរ។ ដោយឡែកពិធីបុណ្យទានដែលប្រជាជនធ្វើក្នុងសហគមន៍ តែងតែធ្វើឡើងអាស្រ័យទៅលើធនធានដែលមានក្នុងសហគមន៍។ ពិធីដែលតែងតែធ្វើនោះទៀតសោត គឺពុំមានកំណត់ជាពេលវេលាជាក់លាក់ណាមួយឡើយ ដោយអាស្រ័យទៅតាមចាស់ទុំ ឬអ្នកដឹកនាំកម្មវិធី រួមទាំងមតិភាគច្រើនរបស់ប្រជាជនក្នុងសហគមន៍នោះប៉ុណ្ណោះ។

បើក្រឡេកមកមើលតំបន់មួយដែលគេហៅថា កម្តេច ដែលស្ថិតក្នុង ភូមិកោះកេរ ឃុំស្រយង់ ស្រុកគូលែន ខេត្តព្រះវិហារ មានប្រជាជនរស់ប្រមាណ ៧៨គ្រួសារ។ តំបន់នេះតែងតែមានពិធីបុណ្យនានាទៅតាមរដូវកាល ក្នុងនោះដែរមានពិធីបុណ្យមួយដែលតែងធ្វើឡើងក្នុងកំឡុង ខែធ្នូ និងខែមករា ដែលអ្នកស្រុកតែងហៅថា បុណ្យភូមិ ឬបុណ្យកំសាន្តភូមិ។ បុណ្យភូមិ គឺធ្វើឡើងជារៀលរាល់ឆ្នាំ ក្រោយពេលដែលប្រជាជនប្រមូលផលពីការធ្វើកសិកម្មរួចរាល់។ អ្នកស្ថិតក្នុងតំបន់នេះយល់ថាកាលដែលប្រារព្ធពិធីបុណ្យភូមិនេះឡើង គឺដើម្បីធ្វើកិច្ចសែនព្រេនរំលឹកគុណទៅកាន់អ្នកថែរក្សាម្ចាស់ទឹកម្ចាស់ដីដែលតែងថែរក្សាក្នុងតំបន់របស់ពួកគេរស់នៅ។ មួយវិញទៀត ពិធីបុណ្យនេះគេតែងធ្វើឡើងក្រោយពេលប្រមូលផលស្រូវរួចរាល់។ ព្រោះថា ទោះបីជាមនុស្សរស់នៅតំបន់នេះ ស្ថិតក្នុងតំបន់ខ្ពង់រាបសំបូរព្រៃឈើ ដែលភាគច្រើនអាស្រ័យផលទៅលើដំណាំកសិកម្មតាមបែបចម្ការ និងអាស្រ័យផលព្រៃឈើយ៉ាងណាក្តី ក៏ពួកគាត់នៅតែមានជំនឿទៅលើពិធីដែលទាក់ទងនិងស្រូវដែរ។ ពោលគឺស្រូវ បានប្រែក្លាយជាបាយដែលជាប្រភពអាហារសំខាន់ប្រចាំថ្ងៃសម្រាប់ពួកគាត់។ ដូចនេះហើយបានជាក្នុងពិធីបុណ្យនេះមានផ្នែកមួយដែលទាក់ទងនិងស្រូវ គឺការប្រមូលស្រូវរួមគ្នាដើម្បីធ្វើបុណ្យភូមិ។ ដោយសារតែប្រជាជនក្នុងតំបន់នេះមានគោរពប្រតិបត្តិព្រះពុទ្ធសាសនា ទើបបានជាពួកគាត់ធ្វើពិធីបុណ្យនេះរួមបញ្ចូលគ្នាជាមួយជំនឿជីវចលរបស់ខ្លួន ហើយបានប្រែក្លាយជាប្រពៃណីទំនៀមទម្លាប់មួយប្រចាំក្នុងតំបន់នេះ។

អត្ថបទដោយ៖ ព្រាន់ សុភារៈ និង**ថូ ថុន**

ពិធីបុណ្យនេះគេធ្វើឡើងនៅសាលាឆទានកណ្តាលភូមិរួមមួយ ដែលគេបានសាងសង់សម្រាប់ធ្វើបុណ្យរួមក្នុងតំបន់នោះ។ ជានិច្ចកាលគេប្រារព្ធពិធីបុណ្យនេះរយៈពេលពីរថ្ងៃ ដោយនៅពេលល្ងាចថ្ងៃទីមួយ ប្រជាជនបានជួបជុំគ្នានៅម៉ោងប្រមាណ ២រសៀល ដើម្បីរៀបចំស្វាធម៌ បាយសី និងគ្រឿងរណ្តាប់ផ្សេងៗ (រូបលេខ១-២)។ មុននឹងឈានទៅដល់កិច្ចដែលគេបានរៀបចំ ឃើញថាមានប្រជាជននៅតំបន់នោះបាននាំគ្នាយករបស់របរមកជួយបុណ្យដូចជា ស្រូវ ប្រាក់ និងគ្រឿងភេសជ្ជៈមួយចំនួនទៀត (រូបលេខ៣-៤)។ កិច្ចដំបូងគេធ្វើក្នុងពិធីបុណ្យនេះនៅថ្ងៃទីមួយ គេចាប់ផ្តើមធ្វើកិច្ចលើកទង់ នៅម៉ោង៣រសៀល ដោយមានអ្នកចូលរួមបានយកលុយទៅដាក់ក្នុងហោប៉ៅទង់ដែលគេហៅថាបូជាបច្ច័យរួចលើទង់នោះឡើងដាក់នៅខាងមុខសាលាឆទានចំនួនពីរទង់ (រូបលេខ៥-៦)។ ជាកិច្ចបន្ទាប់នៅម៉ោង៤រសៀល គេជួបជុំគ្នានៅពីមុខរានពិធីស្ថិតនៅជ្រុងទិសឦសាន ដើម្បីធ្វើកិច្ចប្រុងពលីដែលមានអាចារ្យម្នាក់ជាអ្នកដឹកនាំ (រូបលេខ៧)។ បន្ទាប់ពីធ្វើកិច្ចប្រុងពលីរួចរាល់គេនិមន្តព្រះសង្ឃ ដើម្បីធ្វើកិច្ចចម្រើនព្រះបរិត្ត និងវេភេសជ្ជៈ ជូនព្រះសង្ឃជាកិច្ចចុងបញ្ចប់ក្នុងថ្ងៃទី១ (រូបលេខ៨)។ នៅថ្ងៃទីពីរ មុនម៉ោង៧ព្រឹក គេឃើញមានកិច្ចមួយហៅថាកិច្ចសែនម្ចាស់ទឹកម្ចាស់ដី ដើម្បីសុំសេចក្តីសុខ ក្នុងនោះមានសំណែនជា បាយ សម្ល បង្អែម និងម្ហូរស្ងោ ហើយកិច្ចនេះគេធ្វើឡើងនៅខាងក្រៅសាលាឆទាន ពោល គឺនៅទិសឦសាននៃសាលាឆទាននោះ (រូបលេខ៩)។ ជាកិច្ចបង្ហើយបុណ្យ ក្នុងពិធីបុណ្យភូមិនេះ គេនិមន្តព្រះសង្ឃឆាន់ចង្ហាន់ពេលព្រឹក បន្ទាប់មកគេធ្វើកិច្ចច្រើនធម៌ទេសនានៅម៉ោង៨ព្រឹក។ ក្រោយមកគេបានរៀបចំចង្ហាន់នៅម៉ោង៩ព្រឹក ហើយធ្វើកិច្ចនមសិកា វេចង្ហាន់ប្រគេនព្រះសង្ឃឆាន់នៅម៉ោង១១ថ្ងៃត្រង់ជាកិច្ចបង្ហើយបុណ្យ (រូបលេខ១០)។

អត្ថបទដោយ៖ ព្រាន់ សុភារៈ និង**ថូ ថុន**

សង្ខេបមកអ្នកចូលរួមក្នុងពិធីបុណ្យភូមិ គឺជាប្រជាជនក្នុងតំបន់ដែលតែងតែប្រារព្ធពិធីបុណ្យនេះជារៀលរាល់ឆ្នាំ ពោលនៅពេលដែលរួចរាល់ពីការងារធ្វើស្រែចម្ការ និងប្រមូលផលរួចរាល់។ មិនតែប៉ុណ្ណោះ ការប្រារព្ធធ្វើពិធីបុណ្យនេះ បានបង្ហាញពីប្រពៃណីទំនៀមទម្លាប់របស់ប្រជាជនក្នុងតំបន់នេះដែលមានការលាយបញ្ចូលគ្នារវាងជំនឿជីវចល និងព្រះពុទ្ធសាសនា៕




*រូបលេខ១ និង២៖ សកម្មភាពរៀបចំគ្រឿងរណ្តាប់ផ្សេងៗ*




*រូបលេខ៣ និង៤៖ ប្រជាជនយកស្រូវមកចូលបុណ្យ*

អត្ថបទដោយ៖ ព្រាន់ សុភារៈ និងថូ ថុន




រូបលេខ៥ និង៦៖ ប្រជាជនលើកទង់មុខសាលាឆទាន



រូបលេខ៧៖ កិច្ចប្រុងពលី



រូបលេខ៨៖ កិច្ចចម្រើនព្រះបរិត្ត



រូបលេខ៩៖ កិច្ចសែនព្រេនម្ចាស់ទឹកដី



រូបលេខ១០៖ វេចង្ហាន់ប្រគេនព្រះសង្ឃ

អត្ថបទដោយ៖ ព្រាន់ សុភារៈ និងថូ ថុន